ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

លេខៈ ០២ សកអ

ភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

# សារាចរណែនាំ
# ស្តីពី
# ការបន្តអនុវត្តន៍គោលនយោបាយសោធនធានារ៉ាប់រងសង្គម និងសង្គ្រោះសង្គម

កន្លងមកក្រសួងស្ថាប័ន ខេត្ត ក្រុង បានយកចិត្តទុកដាក់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលបានល្អប្រសើរតាមសេចក្តីសម្រេចដូចខាងក្រោម ៖

- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ១៨៤ សសរ ចុះថ្ងៃទី ២៥-១២-៩០ ស្តីពីរបបសោធននិវត្តន៍ និងរបបសោធនបាត់បង់សមត្ថភាពពលកម្មចំពោះកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ។
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ២៤៥ សសរ ចុះថ្ងៃទី ០៥-១១-៨៨ ស្តីពីរបបគោលនយោបាយធានារ៉ាប់រងសង្គម សម្រាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម។
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ៧៩ សសរ ចុះថ្ងៃទី ២៣-០៦-៨៧ ស្តីពីរបបគោលនយោបាយចំពោះទារកកំព្រា កុមារកំព្រា ជនជរា ពិការ ជនអនាថា ស្នាក់នៅមជ្ឈមណ្ឌលរបស់រដ្ឋ។
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ២០ សសរ ចុះថ្ងៃទី ៣០-០១-៩១ ស្តីពីរបបគោលនយោបាយជនពលី ពិការ និងសេចក្តីណែនាំអនុវត្តរបស់ក្រសួងយុទ្ធជនពិការ សង្គមកិច្ច លេខ ១២១ សណន ចុះថ្ងៃទី ០១-១២-៩១
- លិខិតលេខ ១៥២ សជណអជ ចុះថ្ងៃទី ២៧-០១-៩៥ របស់គណៈរដ្ឋមន្ត្រី សំណើសុំសម្រេចលើការអនុវត្តន៍ជាបណ្តោះអាសន្ន ចំពោះការដោះស្រាយសំណុំលិខិតអ្នកចូលនិវត្តន៍ និងបាត់បង់សមត្ថភាពពលកម្មផ្នែកអ្នករាជការស៊ីវិល។

ដើម្បីបន្តអនុវត្តសេចក្តីសម្រេចខាងលើអោយបានសមស្របគោលការណ៍កែទម្រង់រចនាសម្ព័ន្ធទូទៅរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី និងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន សូមធ្វើការណែនាំដូចខាងក្រោម ៖

I. **ការងារសោធន**

នៅពេលមិនទាន់មានគោលការណ៍លម្អិតអនុវត្តច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងដោយបានការឯកភាពតាមស្មារតីប្រជុំរវាងក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ កាលពីថ្ងៃទី ១៥-១១-៩៤ ការអនុវត្តន៍គោលនយោបាយសោធននៅតែដំណើរការបន្តជាបណ្តោះអាសន្នតាមគោលការណ៍ចាស់ដដែលប៉ុន្តែលក្ខខណ្ឌអាយុចូលនិវត្តន៍របស់នារីត្រូវកំណត់ ៥៥ ឆ្នាំ ដូចបុរសដែរ។

**១.ក្រសួងស្ថាប័ន មានភារកិច្ច** :

- សម្រេចអោយចូលនិវត្តន៍ ឬចូលបាត់បង់សមត្ថភាពពលកម្ម ចំពោះមន្ត្រីរាជការស៊ីវិលដែលនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ខ្លួនដោយពុំចាំបាច់មានពាក្យស្នើសុំពីសាមីខ្លួនឡើយ។
- ផ្តល់សំណុំលិខិតចាំបាច់ដូចមាននៅក្នុងបញ្ជីឧបសម្ព័ន្ធ I ទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន បីខែមុនពេលកំណត់អោយមន្ត្រីរាជការនោះ ចូលនិវត្តន៍ ឬបាត់បង់សមត្ថភាពពលកម្ម។ ចំពោះករណីយឺតយ៉ាវពុំទទួលខុសត្រូវឡើយ។
- រៀងរាល់ឆ្នាំត្រូវធ្វើគម្រោងផែនការស្ថិតិមន្ត្រីរាជការដែលត្រូវចូលនិវត្តន៍ ឬចូលបាត់បង់សមត្ថ-ភាពពលកម្ម ទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន អោយបានមុនដំណាច់ខែ ៨។

**២. អធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត ក្រុង មានភារកិច្ច**:

- ធ្វើសំណើសុំសៀវភៅសោធនថ្មី ទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជននៅពេលសៀវ-ភៅសោធនថ្មីប្រើអស់ ឬបាត់។
- ធ្វើសំណើផ្ទេរនិវត្តជន ឬជនបាត់បង់សមត្ថភាពពលកម្ម ទៅខេត្ត ក្រុងផ្សេងៗទៀតតាមសំណើរបស់មុខសញ្ញា បញ្ជូនសំណុំលិខិត ទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន។
- ធ្វើសំណើសុំចេញអត្តសញ្ញាណប័ណ្ណនិវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម ដោយមានភ្ជាប់បញ្ជីរាយនាម និងអត្តលេខមុខសញ្ញាផង ទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន។
- ចុះទិដ្ឋាកាថ្មីក្នុងសៀវភៅសោធន នៅពេលមានការប្តូរប្រាក់បៀវត្សថ្មី ដោយផ្អែកតាមការណែនាំរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន។
- បើកប្រាក់សោធនជូននិវត្តជន ឬជនបាត់បង់សមត្ថភាពពលកម្មក្នុងមួយខែម្តង បើកប្រាក់ឆ្លងតាមរយៈក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន។
- ធ្វើសំណើលុបឈ្មោះនិវត្តនជន ឬជនបាត់បង់សមត្ថភាពពលកម្មដែលបាន ដោយភ្ជាប់មកជាមួយនូវសំបុត្រមរណៈភាពទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន។

II. **ការងារធានារ៉ាប់រងសង្គម** :

គោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល នគរបាល និងកងយោធពលខេមរ-ភូមិន្ទនៅតែអនុវត្តតាមគោលការណ៍ចាស់ដដែល ប៉ុន្តែក្រសួងស្ថាប័ន និងអធិការដ្ឋានសង្គមកិច្ច ការងារ និងអតីត-យុទ្ធជនខេត្ត ក្រុង ត្រូវមានភារកិច្ចដូចខាងក្រោម :

១. ក្រសួងស្ថាប័នស៊ីវិល ត្រូវធ្វើសំណើសុំប្រាក់ធានារ៉ាប់រងសង្គម សម្រាប់គ្រួសារសព មន្ត្រីរាជការដូចមានក្នុងឧបសម្ព័ន II ជូនភ្ជាប់មកជាមួយនេះ ទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន។

២. ក្រសួងមហាផ្ទៃ និងក្រសួងការពារប្រទេស ត្រូវធ្វើសំណើសុំប្រាក់ឧបត្ថម្ភ និងផ្ទេរកូនកំព្រាពីជនមរណៈនៃនគរបាល កងយោធពលខេមរភូមិន្ទដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ III ទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន។

៣. រៀងរាល់ឆ្នាំ ក្រសួងស្ថាប័ននីមួយៗ ត្រូវផ្តល់ផែនការស្ថិតិកូនកំព្រាពីសពមន្ត្រីរាជការស៊ីវិល និងជនមរណៈនៃនគរបាល និងកងយោធពលខេមរភូមិន្ទ ទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនអោយបានមុនដំណាច់ខែ សីហា។

**៤. អធិការដ្ឋានក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត ក្រុង ត្រូវ៖**

- ធ្វើសុំណើទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ដើម្បីពិនិត្យសម្រេចនៅពេលមុខសញ្ញាសុំផ្លាស់ប្តូរទីលំនៅ ដោយភ្ជាប់មកនៅជាមួយនូវសៀវភៅ ប័ណ្ណ និងវិញ្ញាប័ត្រផ្តាច់ប្រាក់ឧបត្ថម្ភ។
- ធ្វើសំណើទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ដើម្បីពិនិត្យផ្តល់សៀវភៅ ឬប័ណ្ណជាថ្មីនៅពេលសៀវភៅបើកប្រាក់ឧបត្ថម្ភប្រើអស់ ឬបាត់ដោយភ្ជាប់មកនៅជាមួយនូវកំណត់ហេតុនៃការបាត់សៀវភៅ ឬប័ណ្ណ។
- ធ្វើសំណើសុំប្រាក់ឧបត្ថម្ភមុខសញ្ញាគោលនយោបាយក្នុងមួយខែម្តង ហើយបញ្ជីបើកប្រាក់ឧបត្ថម្ភមុខសញ្ញា ទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន។
- ធ្វើសំណើទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ដើម្បីពិនិត្យផ្តាច់ប្រាក់ឧបត្ថម្ភកូនកំព្រាដែលមានអាយុ ១៥ឆ្នាំឡើងទៅ ហើយគ្មានលិខិតបញ្ជាក់ការសិក្សា ដោយភ្ជាប់ជាមួយបញ្ជីរាយនាម និងសៀវភៅបើកប្រាក់ឧបត្ថម្ភផង។

III. **ការងារសង្គ្រោះសង្គម** :

ទិសដៅរបស់ក្រសួងចាប់ពីឆ្នាំ ១៩៩៥ នេះតទៅ យើងមិនពង្រីកបរិមាណក្មេងកំព្រាតាមមណ្ឌលដែលរដ្ឋគ្រប់គ្រងទេ លុះត្រាតែមានករណីពិសេសជៀសមិនរួច ព្រោះប្រទេសជាតិមានស្ថេរភាពនយោបាយ និងសន្តិសុខជាបង្គួរហើយ។

ដើម្បីអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ៧៩ សសរ ចុះថ្ងៃទី ២៦-០៦-៨៧ អោយមានដំណើរការជាប្រក្រតី ក្រសួងធ្វើការកែសម្រួលលើចំណុចខ្លះ នៃប្រកាសលេខ ២០១៨ យស.ចស ចុះថ្ងៃទី ១០-១០-៨៧ គឺស្តីពីការបញ្ចូល ឬបញ្ចេញកុមារ និង ការស្នើប្រាក់ឧបត្ថម្ភប្រចាំខែជូនមុខសញ្ញាសង្គ្រោះសង្គមទៅតាមមជ្ឈមណ្ឌលសង្គ្រោះនានារបស់រដ្ឋ និងការបង្កើតមជ្ឈមណ្ឌលសង្គ្រោះអធិការដ្ឋានសង្គមកិច្ច កាងារ និង អតីត-យុទ្ធជនខេត្ត-ក្រុង ត្រូវធ្វើសំណើទៅសុំសេចក្តីសម្រេចពីក្រសួងសង្គមកិច្ច កាងារ និងអតីតយុទ្ធជន ជាមុនសិនទើបអនុវត្តបាន។ ដូចមានសំណុំលិខិតជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ IV។ ចំពោះមជ្ឈមណ្ឌលក្រោមការគ្រប់គ្រងផ្ទាល់របស់នាយកដ្ឋានចូលនិវត្តន៍សង្គ្រោះសង្គម “មជ្ឈមណ្ឌលកុមារកំព្រាគៀនឃ្លាំង” ការបញ្ចេញកុមារ និងការស្នើសុំប្រាក់ឧបត្ថម្ភប្រចាំខែ ក៏ត្រូវសុំការសម្រេចពីក្រសួងជាមុនដូចគ្នាដែរ។

IV. **ការងារគ្រប់គ្រងមុខសញ្ញាគោលនយោបាយ** :

**១. អធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ត្រូវ :**

- ណែនាំគ្រប់មជ្ឈមណ្ឌលសង្គ្រោះ ដោយកំណត់អោយមុខសញ្ញាទាំងអស់ធ្វើកិច្ចសន្យាដោយផ្ទាល់ថា គេពុំមានសិទ្ធិទាមទារអ្វីទាំងអស់ពីរដ្ឋ ហើយនៅពេលដែលគេមានអាយុ ១៨ ឆ្នាំឡើងដោយមិនបន្តការសិក្សាទៀតនោះ ត្រូវចេញពីមណ្ឌលទៅរស់នៅតាមសហគមន៍ ហើយទទួលខុសត្រូវដោយខ្លួនឯង។
- ធ្វើរបាយការណ៍ពីលទ្ធផលនៃការអនុវត្តន៍គោលនយោលបាយខាងលើប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ឆ្នាំ ទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន អោយបានទៀងទាត់តាមការកំណត់។
- មានកម្មវិធីការងារស្វែងយល់ ស្ថានភាព ជីវភាពមុខសញ្ញាគោលនយោបាយប្រចាំខែ និងរិះរកវិធីដោះស្រាយអោយសមស្រប ក្នុងករណីមុខសញ្ញាជួបការលំបាក ឬមានការប្រែប្រួល។
- ផ្តល់គម្រោងផែនការថវិកា មុខសញ្ញាគោលនយោបាយប្រចាំឆ្នាំ ទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន អោយបានមុនដំណាច់ខែ សីហា។

**១. នាយកដ្ឋានចូលនិវត្តសង្គ្រោះសង្គម មានភារកិច្ច :**

- ណែនាំការអនុវត្តន៍ជាក់ស្តែងគោលនយោលបាយខាងលើដល់មន្ត្រីជំនាញតាមបណ្តាផ្នែកនៃក្រសួងស្ថាប័ន និងនាយកដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត ក្រុង ដើម្បីអោយការអនុវត្តន៍ទទួលបានប្រសិទ្ធភាពខ្ពស់។
- តាមដានត្រួតពិនិត្យ វាយតម្លៃ ការអនុវត្តន៍គោលនយោបាយគ្រប់ខេត្ត ក្រុង អោយបានពីរដងក្នុងមួយឆ្នាំ កំណត់ពេលវេលាក្នុងឆមាសទី១ និងឆមាសទី២។
- បូកសរុបលទ្ធផលការអនុវត្តន៍គោលនយោបាយជូនក្រសួងប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស ៩ខែ និង ឆ្នាំ អោយបានទៀងទាត់តាមការកំណត់។
- ធ្វើគម្រោងផែនការ ថវិកា ជូនក្រសួង អំពីការងារគោលនយោបាយស្ថិតិក្រោមសមត្ថកិច្ចរបស់ខ្លួន។

សារាចរណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ**
**និងអតីតយុទ្ធជន**
**អនុរដ្ឋលេខាធិការ**

**ហត្ថលេខា និងត្រា**

**ហុង ថែម**

**ចម្លងជូន** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
  " ដើម្បីជូនជ្រាប "
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់អធិការដ្ឋាន សង្គមកិច្ច ការងារ និងអតីតយុទ្ធជនខេត្ត ក្រុង
  "ដើម្បីសហការអនុវត្ត"
- កាលប្បវត្តិ - ឯកសារ

# ឧបសម្ព័ន្ធ l

## សំណុំលិខិតរបស់ក្រសួង ស្ថាប័ន

## ផ្ញើ

## ទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

- លិខិតសុំចេញសៀវភៅសោធនរបស់ក្រសួង ស្ថាប័ន ចំនួន................................................២ ច្បាប់
- ប្រកាសឱ្យចូលនិវត្តន៍ ឬ ចូលបាត់បង់សមត្ថភាពពលកម្ម ក្រសួង ស្ថាប័ន ចំនួន............................២ ច្បាប់
- លិខិតបញ្ជាក់អំពីរយៈពេលបំពេញការងាររបស់មន្ត្រីរាជការ ចេញដោយប្រធានស្ថាប័ន ចំនួន............២ ច្បាប់
- ជីវប្រវត្តិ ចំនួន..........................................................................................................២ ច្បាប់
- រូបថត ៤ គុណ ៦ ចំនួន ..........................................................................................៤ សន្លឹក
- បើមានមន្ត្រីរាជការនៅកន្លែងប៉ះពាល់ខុសភាព មុនពេលចូលនិវត្តន៍ ឬចូលបាត់បងសមត្ថភាពពលកម្ម ត្រូវមានលិខិតបញ្ជាក់ការងារប៉ះពាល់សុខភាពរបស់ប្រធានស្ថាប័នដោយផ្អែកតាមសេចក្តីកំណត់អំពីការងារធ្ងន់ ការងារពិបាក ការងារប៉ះពាល់សុខភាពរបស់ក្រសួងសុខាភិបាល ចំនួន.....................................១ ច្បាប់
- បើសិនបាត់បង់សមត្ថភាពពលកម្ម ដោយមានជំងឺរ៉ាំរ៉ៃ ពុំមែនគ្រោះថ្នាក់ការងារ ឬ បេសកកម្មត្រូវមានវិញ្ញាបនប័ត្រ វាយតម្លៃសុខភាពចេញដោយក្រសួងសុខាភិបាល ចំនួន .....................................១ ច្បាប់
- ដោយឡែកជនបាត់បង់សមត្ថភាពពលកម្ម ដោយគ្រោះថ្នាក់ការងារ ឬបេសកកម្មត្រូវមានកំណត់ហេតុអំពីគ្រោះថ្នាក់ ឬលិខិតបញ្ជាក់ពីស្ថាប័ន ចំនួន.........................................................................១ ច្បាប់

# ឧបសម្ព័ន្ធ ॥

# សំណុំលិខិតគោលនយោបាយរបស់ក្រសួង ស្ថាប័ន ផ្ញើទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន សម្រាប់កូនកំព្រាពីសពមន្ត្រីរាជការស៊ីវិល

– ពាក្យស្នើសុំប្រាក់ធានារ៉ាប់រងសង្គមជូនគ្រួសារសព ចំនួន..................................................២ ច្បាប់

– ប្រកាសលុបឈ្មោះមន្ត្រីរាជការ ចេញពីក្របខ័ណ្ឌរដ្ឋ ចំនួន..................................................២ ច្បាប់

– ពាក្យសុំស្នើសុំផ្ទេរប្រាក់ឧបត្ថម្ភកូនកំព្រាពីសព ចំនួន........................................................២ ច្បាប់

– វិញ្ញាបនប័ត្រផ្តាច់ប្រាក់ពីសព ចំនួន.....................................................................២ ច្បាប់

– សំបុត្រមរណៈភាព ចំនួន...............................................................................២ ច្បាប់

– តារាងរៀបរាប់ស្ថានភាពគ្រួសារសព ចំនួន..............................................................២ ច្បាប់

– កំណត់ហេតុអំពីគ្រោះថ្នាក់ការងារ ឬបេសកកម្ម បញ្ជាក់ពីគ្រោះថ្នាក់ការងារ ឬបេសកកម្ម ចំនួន.........២ ច្បាប់

– លិខិតបញ្ជាក់ការសិក្សាចំពោះកូនមានអាយុ ១៥ឆ្នាំឡើង ចំនួន.............................................២ ច្បាប់

# ឧបសម្ព័ន្ធ III
# សំណុំលិខិតកូនជនមរណៈ នៃនគរបាល និងកងយោធពលខេមរភូមិន្ទ ផ្ញើទៅ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

- ពាក្យស្នើចេញប័ណ្ណ និងសៀវភៅបើកប្រាក់ឧត្ថម្ភ ចំនួន ....................................................២ ច្បាប់
- ប្រកាសលុបឈ្មោះជនមរណៈ ចេញពីក្របខ័ណ្ឌ របស់ក្រសួងការពារប្រទេស ឬក្រសួងមហាផ្ទៃ ចំនួន..២ ច្បាប់
- លិខិតជូនដំណឹងមរណៈភាព ចំនួន..........................................................................២ ច្បាប់
- តារាងរៀបរាប់ស្ថានភាពគ្រួសារសព ចំនួន.................................................................២ ច្បាប់
- លិខិតបញ្ជាក់ការសិក្សាចំពោះកូនអាយុ ១៩ ឆ្នាំឡើង ចំនួន...................................................២ ច្បាប់

# ឧបសម្ព័ន្ធ IV

## សំណុំលិខិត ស្នើបញ្ជូនទារកកំព្រា កុមារកំព្រា

- ពាក្យស្នើសុំបញ្ជូន ឬ បញ្ចេញរបស់អធិការដ្ឋានសង្គមកិច្ច ការងារ និង អតីតជន ខេត្ត ក្រុង ចំនួន.....២ ច្បាប់
- ពាក្យស្នើសុំបញ្ចូលរបស់បុគ្គល ឬស្ថាប័នចំពោះទារក ឬកុមារដែលគ្មានទីពឹង ដោយភ្ជាប់មកជាមួយនូវកំណត់ហេតុ នៃការរើសទារក ឬកុមារព្រមទាំង មានការបញ្ជាក់ទទួលស្គាល់ពីរដ្ឋអំណាចមូលដ្ឋាន ភូមិ សង្កាត់ ចំនួន......................................២ ច្បាប់
- ចំពោះកុមារនៅតាមគ្រួសារ អាណាព្យាបាល ត្រូវមានពាក្យស្នើសុំពីគ្រួសារ អាណាព្យាបាលនោះ សេចក្ដី ពីភូមិ ឃុំ សង្កាត់ និង សេចក្ដីសន្និដ្ឋាន វាយតម្លៃស្ថានភាពរស់នៅពីភ្នាក់ងារសង្គមកិច្ច នៅមូលដ្ឋាននោះផង ចំនួន...............................២ ច្បាប់
- ជីវប្រវត្តិសង្ខេប ចំនួន...................................................................................២ ច្បាប់
- កិច្ចសន្យារបស់មុខសញ្ញា ឬគ្រួសារ អាណាព្យាបាល “បើកុមារអាយុតិចជាង ៦ ឆ្នាំ” ចំនួន..............២ ច្បាប់
- លិខិតបញ្ជាក់ការសិក្សា បើសិនជាកុមារនៅរៀន ចំនួន......................................................២ ច្បាប់
- រូបថត “បើសិនជាមាន”